## សេចក្តីប្រកាសរួម

## ស្តីអំពី

## ការបើកអោយដំណើរការការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ដោយឯកឧត្តម ស៊ាន វិសុទ្ធ ប្រធានការិយាល័យរដ្ឋបាល និង លោកស្រី មីសែល លី អនុប្រធានការិយាល័យរដ្ឋបាល**

ការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកអោយដំណើរការក្នុងសប្តាហ៍នេះហើយ ចំណែកក្រុមចាប់ផ្តើមការងាររួមក៏កំពុងចាប់ផ្តើមការងាររបស់ពួកគេដែរ ។

យើងខ្ញុំមានសេចក្តីរីករាយណាស់ក្នុងការទទួលស្វាគមន៍អ្នកសារព័ត៌មានជាលើកដំបូង នៅក្នុងទីតាំងអគារធ្វើការថ្មីរបស់យើង រួមមានអគារការិយាល័យមួយ និងសាលសវនាការមួយដែលប្រកបទៅដោយទីធ្លាធំទូលាយ ហើយឥឡូវនេះនឹងត្រូវបានដាក់អោយប្រើប្រាស់ជាអគារធ្វើការ សំរាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសំរាប់កាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។

យើងអាចនិយាយបានយ៉ាងច្បាស់ថា យើងបានឆ្លងពីដំណាក់កាលរៀបចំ ហើយឈានចូលដល់ការបង្កើតជាក់ស្តែងនូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រឺ ECCC ។

ឆ្លៀតក្នុងឱកាសនេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណដល់ម្ចាស់អំណោយទាំងអស់ ទាំងចំពោះអ្នកដែលបានចូលរួមវិភាគទានជាថវិកាតាមរយៈអង្គការសហប្រជាជាតិ និងទាំងចំពោះអ្នកដែលបានចូលរួមវិភាគទានជាថវិកាតាមរយៈភាគីកម្ពុជា ដែលនៅខ្វះខាតប្រមាណ ៩.៦លានដុល្លារទៀត ។ យើងខ្ញុំមានការជឿជាក់ថា មូលនិធិដែលនៅសេសសល់ នឹងត្រូវបានធានាក្នុងពេលឆាប់ៗនេះ ហើយយើងខ្ញុំសូមធ្វើការអំពាវនាវម្តងទៀតសំរាប់ការផ្តល់ជំនួយផ្នែកវិភាគទាននេះ ។

យើងខ្ញុំមិនបណ្តោយអោយកង្វះខាតនាពេលបច្ចុប្បន្ន រាំងស្ទះដល់ការបើកអោយដំណើរការរបស់ការិយាល័យរដ្ឋបាល និងផ្តើមការងាររបស់ក្រុមការងាររួមសំរាប់ការិយាល័យរដ្ឋបាលនេះទេ ។ ដៃគូរបស់យើងខ្ញុំមកពីអង្គការសហប្រជាជាតិ ដែលដឹកនាំដោយលោកស្រី **មីសែល លី** អនុប្រធានការិយាល័យរដ្ឋបាលបានចាប់ផ្តើមធ្វើដំណើរមកដល់ទីក្រុងភ្នំពេញដើម្បីទទួលការងាររបស់ពួកគេនៅ ECCC នេះ ។

ចំពោះផ្នែកច្បាប់ និងតុលាការ ដំណាក់កាលចុងក្រោយនៃការតែងតាំងចៅក្រមជាតិ និងអន្តរជាតិ សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតកំពុងតែដំណើរការ ហើយយើងខ្ញុំរំពឹងទុកថានឹងអាចប្រកាសឈ្មោះរបស់ពួកគេក្នុងពេលដ៏ឆាប់ខាងមុខនេះ។ កាលពីថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៦ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តនូវសេចក្តីសំរេចមួយ ក្រោមការផ្តល់អនុសាសន៍ពីអគ្គលេខាធិការ ដែលសំរេចថាចៅក្រមអន្តរជាតិ សហព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតអន្តរជាតិទាំងអស់ និងត្រូវចាត់ទុកជាមន្ត្រីរបស់អង្គការសហប្រជាជាតិ សំរាប់បំពេញលើលក្ខខណ្ឌការងាររបស់ពួកគេ ហើយអនុម័តផ្តល់នូវនីតិសម្បទាអោយពួកគេដោយយោងលើលក្ខខណ្ឌនេះ។

ចំពោះភាគីអង្គការសហប្រជាជាតិ មន្ត្រីតុលាការដែលត្រូវបានជ្រើសរើសនោះកំពុងត្រូវបានត្រួតពិនិត្យសុខភាព ហើយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានរំពឹងទុកថា នឹងផ្តល់បញ្ជីឈ្មោះអ្នកដែលត្រូវតែងតាំងដល់រាជរដ្ឋាភិបាលកម្ពុជា សំរាប់ការជ្រើសរើសចុងក្រោយនិងតែងតាំង ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ យើងខ្ញុំសង្ឃឹមថាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងប្រកាសក្នុងពេលជាមួយគ្នានូវឈ្មោះមន្ត្រីតុលាការកម្ពុជាដែលនឹងត្រូវតែងតាំង។

ការត្រៀមលក្ខណះផ្សេងៗទៀតក៏កំពុងតែដំណើរការដែរ ដូចជាការរៀបចំបោះពុម្ពឡើងវិញ នូវកូនសៀវភៅការណែនាំស្តីពីការកាត់សេចក្តីមេដឹកនាំខ្មែរក្រហមសំរាប់ការផ្សព្វផ្សាយទូទាំងប្រទេស ការចងក្រងប្រមូលឯកសារច្បាប់ជាមូលដ្ឋាន ចំនួនជាង ១០០ ជាភាសាផ្លូវការនៅក្នុងតុលាការ និងកម្មវិធីផ្សព្វផ្សាយព័ត៌មានតាមតំបន់ (បានទទួលការឧបត្ថម្ភពីរដ្ឋាភិបាលប្រទេសអូស្ត្រាលី និងប្រទេសន័រវេស)។

យើងខ្ញុំដឹងថាភារកិច្ចនៅចំពោះមុខរបស់បុគ្គលិក និងមន្ត្រីតុលាការទាំងអស់ ជាកិច្ចការមួយសំខាន់ដែលចាំបាច់ត្រូវប្រើអោយអស់លទ្ធភាពនូវបទពិសោធន៍ ការប្រឹងប្រែងនិងភាពអត់ធ្មត់ ប៉ុន្តែយើងខ្ញុំសន្យាថា នឹងខិតខំអោយអស់ពីសមត្ថភាពដើម្បីទទួលខុសត្រូវនូវរាល់កាតព្វកិច្ចដែលបានប្រគល់អោយ ក្នុងន័យសបញ្ជាក់ថា ភាពយឺតយូរក្នុងការរកយុត្តិធម៌នឹងមិនមានន័យថា មិនមានយុត្តិធម៌សំរាប់ប្រជាជនកម្ពុជាដែលបានទន្ទឹងរង់ចាំអស់ពេលជាយូរមកហើយនោះទេ។

ធ្វើនៅ ភូមិកន្ទោក ថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ២០០៦
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (បានកែសំរួល)